# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# អង្គបុរេជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ០០១/១៨-០៧-២០០៧ អ.វ.ត.ក/កសចស(០២) កាំង ហ្គេកអ៊ាវ ហៅ ឌុច

**ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨**

**ម៉ោង ១៥:០០នាទី**

**សវនាការជាសាធារណៈ:**

**ប្រកាសសាលដីកា**

**ចៅក្រមជំនុំជម្រះ៖**

លោក ប្រាក់ គឹមសាន ប្រធានអង្គបុរេ

លោក រ៉ូវ៉ាន់ ដោនទីង

លោកស្រី ខាទីនខា ឡាហ៊ូស

លោក ហួត វុទ្ធី

លោក ប៉ែន ពេជ្រសាលី

**ក្រឡាបញ្ជី៖**

លោក ជួន សុភាសី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក វីលៀម ស្មីត

**មេធាវីការពារជនត្រូវចោទឈ្មោះ កាំង ហ្គេកអ៊ាវ**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ

# កិច្ចដំណើរការនីតិវិធី

*(សវនាការចាប់ផ្តើមនៅម៉ោង ១៥:០៥នាទី)*

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

**ប្រធានអង្គបុរេ៖**

សូមអញ្ជើញអង្គុយចុះ ។

សូមអ្នកសារព័ត៌មាន អញ្ជើញចេញ ។

នៅថ្ងៃនេះ អង្គបុរេជំនុំជម្រះនឹងប្រកាសសាលដីកា លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្កេកអ៊ាវ ហៅ ឌុច ។ សាលដីកាដែលយើងប្រកាសនៅពេលនេះ ជាសាលដីកាសង្ខេប ហើយសាលដីកាពិស្តារ យើងនឹងដាក់ចូលនៅក្នុងគេហទំព័រ បន្ទាប់ពីយើងប្រកាសសាលដីកានេះរួច ។

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទទួលបានបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ដែលបានបណ្តឹងប្រឆាំងនឹងដីកាបញ្ជូនជំនុំជម្រះលើករណី កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ បណ្តឹងឧទ្ធរណ៍នេះ បានដាក់នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ ។

I) ប្រវត្តិនីតិវិធី

១) ក្នុងសាលដីការបស់ខ្លួន អង្គបុរេជំនុំជម្រះយោងលើឯកសារទាំងអស់ដែលបានដាក់នៅក្នុងបណ្តឹងឧទ្ធរណ៍ ។

II) ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

២) អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍បានដាក់ដោយអនុលោមតាម វិធាន៧៤ និងវិធាន៧៥ នៃវិធានផ្ទៃក្នុង ។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន ។

III) លក្ខណៈនៃបណ្តឹងឧទ្ធរណ៍

ក) សេចក្តីសន្និដ្ឋានរបស់ភាគី

វាក្យខណ្ឌទី៣: សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា វិសាលភាពនៃការពិនិត្យឡើងវិញ គួរត្រូវកម្រិតត្រឹមពាក្យសុំ ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើង ហើយនៅក្នុងរឿងក្តីនេះ គឺកំហុសចំនួនពីរលើអង្គច្បាប់ ដែលសហព្រះរាជអាជ្ញាបានចោទប្រកាន់ ។

កំហុសទីមួយ គឺការខកខានមិនបានចោទប្រកាន់ ឌុច ពីបទមនុស្សឃាត និងបទទារុណកម្ម អនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ ។ និងកំហុសទីពីរ គឺការខកខានមិនបានចោទប្រកាន់ ឌុច ពីការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងអស់ដែលកើតឡើងនៅស-២១ តាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ ។

វាក្យខណ្ឌទី៤: សហមេធាវីរបស់ជនត្រូវចោទសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ផ្អែកលើការបកស្រាយខុសលើវិធាននៃនីតិវិធីជាធរមាននៅចំពោះមុខ អ.វ.ត.ក ។ ហើយអនុលោម តាមនីតិវិធីដែលដឹកនាំដោយចៅក្រម ចៅក្រមជាអ្នកធ្វើការសម្រេចលើកម្មវត្ថុនៃការជំនុំជម្រះ ។ ក្រុម ការពារក្តីផ្តល់ទឡ្ហីករណ៍ថា សំណើដែលធ្វើឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ អាចធ្វើឡើងនៅក្នុងពេលជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ ដូច្នេះហើយ មិនចាំបាច់បណ្តឹងឧទ្ធរណ៍នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ ។ អង្គបុរេជំនុំជម្រះគួរបដិសេធចោលបណ្តឹងឧទ្ធរណ៍នេះ ដោយសារវាមិនបានផ្តល់មូលដ្ឋានត្រឹមត្រូវលើអង្គច្បាប់ ហើយស្នើឱ្យអង្គបុរេជំនុំជម្រះបញ្ជូនសំណុំរឿងទៅ អង្គជំនុំ-ជម្រះសាលាដំបូង ។ សហមេធាវីការពារក្តីរក្សាសិទ្ធិលើកឡើងបញ្ហាវិវាទលើដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងនេះ នៅពេលជំនុំជម្រះ ។

ខ) សេចក្តីពិចារណា

១) វិសាលភាពនៃការពិនិត្យឡើងវិញ

វាក្យខណ្ឌ៥: វិធានផ្ទៃក្នុងមិនបានផ្តល់ការចង្អុលបង្ហាញច្បាស់ថា តើអ្វីទៅជាវិសាលភាពដែលអង្គបុរេជំនុំជម្រះគួរពិនិត្យឡើងវិញ នៅពេលដែលទទួលបានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ ។ ជាងនេះទៅទៀត វិធានផ្ទៃក្នុងមិនបានផ្តល់ការចង្អុលបង្ហាញច្បាស់ ថាតើការពិនិត្យនោះ គួរកម្រិតត្រឹមបញ្ហាដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងឬយ៉ាងណា ក៏ទេដែរ? ។ ច្បាប់កម្ពុជា ក៏មិនបានចែងអំពីបទដ្ឋានណែនាំបន្ថែមទៀត ចំពោះបញ្ហានេះទេ ។

វាក្យខណ្ឌ៦: អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញលក្ខណៈពិសេសនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដីកានេះគឺជាសេចក្តីសម្រេចបញ្ចប់កិច្ចស៊ើបសួរទាំងមូល ដែលនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរនេះ ភាគីទាំងអស់មានលទ្ធភាពចូលរួម ។ ដីកាបែបនេះរួមបញ្ចូលសេចក្តីសន្និដ្ឋានផ្សេងៗ លើអង្គហេតុ និងអង្គច្បាប់ ចំពោះអំពើទាំងអស់ដែលស្ថិតនៅក្រោមការស៊ើបអង្កេត ។ វិសាលភាពដែលបានកម្រិតចំពោះការពិនិត្យឡើងវិញ និងធ្វើឱ្យអង្គបុរេជំនុំជម្រះពិនិត្យឡើងវិញនូវការស៊ើបសួរទាំងមូល

ដោយក្នុងនោះរួមទាំងនិយតភាពនៃនីតិវិធី ដើម្បីអាចឲ្យអង្គបុរេជំនុំជម្រះធ្វើសេចក្ដីសន្និដ្ឋានដោយខ្លួនឯង ។ នៅពេលពិចារណាលើវិធានផ្ទៃក្នុងដែលចែងថា អង្គបុរេជំនុំជម្រះមានតួនាទីជាតុលាការឧទ្ធរណ៍ ហើយជាងនេះទៅទៀត នៅពេលពិចារណាលើរយៈពេលកំណត់ដែលបានចែង អង្គបុរេជំនុំជម្រះយល់ឃើញថា វាមិនមានលក្ខណៈសមស្របក្នុងកម្រិតវិសាលភាពនៃការពិនិត្យឡើងវិញ ចំពោះបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ ។

២) បទដ្ឋាននៃការពិនិត្យឡើងវិញ

វាក្យខណ្ឌ៧: សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គបុរេជំនុំជម្រះធ្វើការកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីបញ្ចូលបទចោទនិងទម្រង់នៃការទទួលខុសត្រូវ ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គ-ហេតុដែលចាំបាច់ដើម្បីធ្វើការសន្និដ្ឋានដូចដែលស្នើឡើង ត្រូវបានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ប៉ុន្តែ សហព្រះរាជអាជ្ញានិដ្ឋានថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានកំណត់បទចោទតាមលក្ខខណ្ឌតម្រូវចេញពីអង្គហេតុទាំងនេះ ។

វាក្យខណ្ឌទី៨: អង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យ តើអ្វីទៅគួរជាបទដ្ឋាននៃការពិនិត្យឡើងវិញនៅក្នុងបណ្ដឹងឧទ្ធរណ៍នេះ? លក្ខណៈនៃសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត នៅពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

វាក្យខណ្ឌ៩: នៅពេលយើងមើលវិធាន៥៥.១ និងវិធាន៥៥.២ ជាមួយនឹងវិធាន៥៣.១ នៃវិធានផ្ទៃក្នុង យើងអាចធ្វើការសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចធ្វើការស៊ើបអង្កេតអង្គហេតុទាំងអស់ ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ។ ចំណុចនេះ វាក៏ដូចនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែរ ។ វិធាន៥៥.៣ នៃវិធានផ្ទៃក្នុងចង្អុលបង្ហាញថា សហចៅក្រមស៊ើបអង្កេតក៏ទទួលបានកាលៈទេសៈជុំវិញអំពើទាំងឡាយ ដែលរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរបន្ថែម ។ កាលៈទេសៈ ដែលគេចោទប្រកាន់ថាឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង ហើយនាំដល់ការកំណត់បទចោទមិនត្រូវបានគេយល់ឃើញថាជាអង្គហេតុថ្មីឡើយ ។ ដូច្នេះហើយ កាលៈទេសៈទាំងនេះជាផ្នែកមួយនៃការស៊ើបសួរ សហចៅក្រមស៊ើបអង្កេតយកបទចោទទាំងនោះ ដែលសហព្រះរាជអាជ្ញាស្នើឡើងមកប្រើប្រាស់ជាត្រីវិស័យក្នុងការកំណត់វិសាលភាពនៃការស៊ើបសួរ ។

វាក្យខណ្ឌ១០: សហចៅក្រមស៊ើបអង្កេតមិនមានយុត្តាធិការក្នុងការស៊ើបសួរអំពើផ្សេងៗឡើយ

លើកលែងតែមានការស្នើសុំពីសហព្រះរាជអាជ្ញា ។ ដូចដែលមានចែងបញ្ជាក់ក្នុងវិធាន៥៥.៣ នៃវិធានផ្ទៃក្នុង ។ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា អនុលោមតាមវិធាន៥៣.៣ នៃវិធានផ្ទៃក្នុង អង្គហេតុថ្មីៗដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានស្ថាពរមិនមែនជាផ្នែកមួយនៃកិច្ចស៊ើបសួរឡើយ។

វាក្យខណ្ឌ១១: វិធាន៦២ នៃវិធានផ្ទៃក្នុងបង្គាប់ថា នៅពេលចេញដីកាដោះស្រាយ សហចៅក្រមស៊ើបអង្កេត ត្រូវតែសម្រេចលើអំពើទាំងអស់ដែលកំណត់ថា ជាផ្នែកមួយនៃកិច្ចស៊ើបសួររបស់ខ្លួន ដោយធ្វើការទាត់ចោលអំពើទាំងនោះ ផ្អែកលើហេតុផលមួយក្នុងចំណោមហេតុផលនានាដែលបានលើកឡើងនៅក្នុងវាក្យខណ្ឌទី៣ ឬក៏បញ្ជូនជនត្រូវចោទទៅជំនុំជម្រះដោយសំអាងលើអំពើទាំងនេះ ។ សេចក្តីសម្រេចនេះ មិនពាក់ព័ន្ធនឹងការអនុវត្តអំណាចឆន្ទានុសិទ្ធិឡើយ ។ នៅពេលមានអាទិភាពនៃកាលៈទេសៈមួយដែលមានចែងក្នុងវិធាន៦២.៣ នៃវិធានផ្ទៃក្នុង ជនត្រូវចោទគួរត្រូវគេបញ្ជូនទៅជំនុំជម្រះ ដោយផ្អែកលើអំពើទាំងនេះ ។ ជំហរនេះក៏ជាជំហរនៅក្នុងមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាផងដែរ ដែលមាត្រានេះចែងថា ប្រសិនបើយល់ឃើញថាអំពើនេះ នោះជាបទឧក្រិដ្ឋមជ្ឈិម ឬលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ។

វាក្យខណ្ឌ១២: សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការទាត់ចោលអំពើទាំងឡាយ ឬបញ្ជូនជនត្រូវចោទទៅជំនុំជម្រះត្រូវផ្តល់សំអាងហេតុដូចមានចែងយ៉ាងច្បាស់ក្នុងវិធាន៦៧.៤នៃវិធានផ្ទៃក្នុង ។ អង្គបុរេជំនុំជម្រះក៏រំឭកផងដែរថា វាជាបទដ្ឋានអន្តរជាតិដែលសេចក្តីសម្រេចរបស់តុលាការទាមទារឱ្យមានការផ្តល់សំអាងហេតុ ។

វាក្យខណ្ឌ១៣: អង្គបុរេជំនុំជម្រះ គួសបញ្ជាក់ថា អំពើទាំងឡាយដែលបានរកឃើញនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ គឺមានលក្ខណៈច្បាស់លាស់អាចឱ្យយកមកសម្រេចសម្រាប់ការកំណត់បទចោទនៅពេលចេញដីកាដោះស្រាយ ដោយមិនគិតពីអង្គហេតុដែលសហព្រះរាជអាជ្ញា បានយមកកំណត់បទចោទពីដំបូងឡើយ ។ អំណាចរបស់អង្គបុរេជំនុំជម្រះក្នុងការបន្ថែមបទចោទ ឬទម្រង់នៃការទទួលខុសត្រូវនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

វាក្យខណ្ឌ១៤: អនុលោមតាមវិធាន៧៩.១ នៃវិធានផ្ទៃក្នុង និងបទប្បញ្ញត្តិនៃក្រមនីតិវិធីនៃព្រះរាជាណាចក្រកម្ពុជា អង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនត្រូវបានផ្តល់អំណាចឱ្យយកការកំណត់បទចោទរបស់ខ្លួនទៅជំនួសការកំណត់បទចោទរបស់សហចៅក្រមស៊ើបអង្កេត ។

នៅពេលធ្វើការសម្រេច ថាតើគួរបន្ថែមបទចោទនិងទម្រង់នៃការចូលរួមប្រព្រឹត្តទាំងនេះ ដូចដែលសហព្រះរាជអាជ្ញាបានស្នើឡើងដែរឬទេនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ? ទោះបីជាយ៉ាងនេះក៏ដោយ អង្គបុរេជំនុំជម្រះក៏ដូចសហចៅក្រមស៊ើបអង្កេតដែរ មានកាតព្វកិច្ចគោរពវិធានច្បាប់ដូចគ្នា ហើយជាពិសេសនោះ គឺវិសាលភាពនៃការស៊ើបសួរ ។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនត្រូវសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ ដោយធ្វើការពិនិត្យមើលថាតើអំពើទាំងឡាយដែលជាផ្នែកមួយនៃការមួយនៃការស៊ើបសួរអាចយកមកកំណត់បទចោទតាមការស្នើឡើងរបស់សហព្រះរាជអាជ្ញាដែរឬទេ? ហើយអង្គបុរេជំនុំជម្រះត្រូវសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ ដោយធ្វើការពិនិត្យមើលថាតើសហចៅក្រមស៊ើបអង្កេតគួរណាស់បញ្ចូលបទចោទនោះដែរឬទេ? ភាពចាំបាច់ក្នុងការបែងចែក ក្នុងការចែកបទល្មើស និងទម្រង់នៃទទួលខុសត្រូវនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

វាក្យខណ្ឌ១៥: សហមេធាវីការពារក្តីរបស់ជនត្រូវចោទសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះមិនចាំបាច់ធ្វើឡើងឡើយ ពីព្រោះអង្គជំនុំជម្រះសាលាដំបូងអាចនឹងធ្វើការដោះស្រាយលើបញ្ហាដែលបានលើកឡើងទាំងនេះ ។

វាក្យខណ្ឌ១៦: វិធាន៦៧.២ នៃវិធានផ្ទៃក្នុងចែងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវចែងអំពីអត្តសញ្ញាណរបស់ជនជាប់ចោទ ការរៀបរាប់អំពីអង្គហេតុ និងបទចោទដែលកំណត់ដោយសហចៅក្រមស៊ើបអង្កេត ដោយក្នុងនោះរួមទាំងបទប្បញ្ញត្តិព្រហ្មទណ្ឌដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។ នៅក្នុងមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មានបទប្បញ្ញត្តិស្រដៀងគ្នាមួយ វិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនមានចែងបទដ្ឋានណែនាំបន្ថែមស្តីពីវិធីសាស្ត្រដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះគួរតែផ្តល់ហេតុផល ។

នៅក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះនឹងអនុវត្តបទដ្ឋានអន្តរជាតិ ។

វាក្យខណ្ឌ១៧: បទដ្ឋានអន្តរជាតិទាមទារឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចែងអំពីអង្គហេតុនៃរឿងក្តី ដោយត្រូវលើឡើងព័ត៌មានពិស្តារ គ្រប់គ្រាន់ដើម្បីជូនដំណឹងជាក់លាក់ដល់ចុងចោទអំពីបទចោទដាក់បន្ទុកលើខ្លួន ដើម្បីឲ្យចុងចោទអាចត្រៀមរៀបចំការពារខ្លួនបាន ។ ដីកាបញ្ជូនរឿងជំនុំជម្រះទៅគួរតែចែងបទចោទនីមួយៗ ឲ្យបានច្បាស់លាស់និងដាច់ដោយឡែកពីគ្នា ហើយគួរកំណត់អំពីជាក់លាក់ទាំងឡាយក្នុងលក្ខខណ្ឌមួយអាចជឿជាក់បាន ។ ប្រសិនបើជនជាប់ចោទត្រូវបានចោទប្រកាន់ពីទម្រង់នៃការចូលរួម ដីកាបញ្ជូនរឿងទៅជំនុំជម្រះគួរចែងអំពីទម្រង់នីមួយៗដែលត្រូវបានចោទប្រកាន់ ។

IV) មូលដ្ឋានទីមួយ: ការខកខានក្នុងការចោទប្រកាន់ឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ

ក) សេចក្តីសន្និដ្ឋានរបស់ភាគី

វាក្យខណ្ឌ១៩: នៅក្នុងមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាផ្តល់ទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់មួយនៅពេលខ្លួនខកខានមិនបានចោទប្រកាន់ ឌុច ពីបទមនុស្សឃាត និងបទទារុណកម្ម ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងផ្តន្ទាទោសតាមមាត្រា៣នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។ ទោះបីជាបទល្មើសទាំងនោះ ត្រូវបានបង្ហាញទាំងស្រុងតាមរយៈអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ ។ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គបុរេជំនុំជម្រះកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយធ្វើការបញ្ចូលបទល្មើសទាំងនេះ ។

វាក្យខណ្ឌ២០: អង្គបុរេជំនុំជម្រះ បានរួមបញ្ចូលសេចក្តីសង្ខេបនៃសេចក្តីសន្និដ្ឋាននានា ។

វាក្យខណ្ឌ២១: សហព្រះរាជអាជ្ញា លើកឡើងសំណើសុំកែប្រែ ចំពោះផ្នែកទីបួននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីបញ្ចូលបទមនុស្សឃាត និងបទទារុណកម្ម ។

វាក្យខណ្ឌ២២: សហមេធាវីការពារក្តីរបស់ជនត្រូវចោទមិនបានឆ្លើយតបជាក់លាក់ចំពោះទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាដាក់ជូន ដែលថាមានការខកខានក្នុងការចោទប្រកាន់បទល្មើសក្រោមច្បាប់ជាតិ ។ ប៉ុន្តែ សហមេធាវីការពារក្តីផ្តោតការព្រួយបារម្ភលើសក្តានុពលដែលថា ការស៊ើបអង្កេតលើបញ្ហានេះ ធ្វើឱ្យមានការពន្យារពេលចំពោះការចាប់ផ្តើមការជំនុំជម្រះ ដោយសហមេធាវីការពារក្តីសួរថា តើសវនាការជំនុំជម្រះលើ ឌុច នឹងចាប់ផ្តើមនៅពេលណា? សហមេធាវីការពារក្តីសន្និដ្ឋានថា ប្រសិនបើអង្គបុរេជំនុំជម្រះនឹងសម្រេចថា គួរតែធ្វើការស៊ើបអង្កេតករណី ឌុច ចំពោះបទល្មើសថ្មី ចំណុចនេះនឹងទាមទារឱ្យ ឌុច ចូលខ្លួនសាជាថ្មី នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ដើម្បីធ្វើឱ្យរឿងក្តីរបស់ ឌុច ពាក់ព័ន្ធនឹងបទចោទថ្មី ។

ការធ្វើដូច្នេះ អាចធ្វើឱ្យមានការពន្យារពេលយ៉ាងយូរ លើការចាប់ផ្តើមការជំនុំជម្រះនៅពេលបញ្ហាទាំងនេះ អាចដាក់នៅចំពោះ មុខអង្គជំនុំជម្រះសម្រាប់ការពិចារណា ។ បន្ថែមពីនេះ សហមេធាវីការពារក្តីយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះមិនមានមូលដ្ឋានតែម្តង ពីព្រោះទឡ្ហីករណ៍ថា ឌុច អាចត្រូវបានតុលាការកាត់ឱ្យរួចខ្លួនមិនសមហេតុ នៅពេលពិចារណាឃើញថា គាត់បានទទួលស្គាល់ការទទួលខុសត្រូវរបស់គាត់ជាច្រើនលើក ច្រើនសា ចំពោះឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្តនៅស-២១ ហើយបានសម្តែងការសោកស្តាយយ៉ាងស្មោះត្រង់ចំពោះជនរងគ្រោះ ។

ខ) សេចក្តីពិចារណា

វាក្យខណ្ឌ២៣: សហចៅក្រមស៊ើបអង្កេត បានពិចារណានៅក្នុងវាក្យខណ្ឌទី១៥២ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះថា អំពើជាក់លាក់មួយចំនួនដែលបានបង្ហាញតាមរយៈការស៊ើបសួរ និងដែលបានកំណត់ថា បទឧក្រិដ្ឋខាងលើអាចត្រូវបានកំណត់យ៉ាងច្បាស់លាស់ផងដែរ ស្របតាមច្បាប់ជាតិកម្ពុជា ជាបទល្មើសមនុស្សឃាតនិងទារុណកម្ម ដែលមានចែងនិងផ្តន្ទាទោសដោយមាត្រា៥០០ មាត្រា៥០១ មាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងដូចមានចែងក្នុងមាត្រា៣(ថ្មី)នៃច្បាប់អ.វ.ត.ក ។ ប៉ុន្តែអំពើទាំងនេះត្រូវតែទទួលបានការចោទប្រកាន់ក្រោមការកំណត់ប្រភេទបទល្មើសដែលមានលក្ខណៈខ្ពស់ជាងគេ ដែលក្នុងករណីនៃសំណុំរឿងនេះ គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ។

វាក្យខណ្ឌ២៤: សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់ហេតុផល ហេតុអ្វីខ្លួនបានចាត់ទុកបទល្មើសក្រោមច្បាប់អន្តរជាតិថា មានការកំណត់បទចោទដែលមានលក្ខណៈខ្ពស់ជាងបទល្មើសក្រោមច្បាប់ជាតិ? ដូចគ្នានេះដែរ សហចៅក្រមស៊ើបអង្កេតមិនបានលើកឡើងមូលដ្ឋានអង្គហេតុដែលខ្លួនយកមកធ្វើជាសំអាងនៅពេលដែលសហចៅក្រមស៊ើបអង្កេតលើកឡើងថា អំពើមួយចំនួនដែលបានកំណត់ដោយកិច្ចស៊ើបសួរក៏បង្កើតជាបទល្មើសក្រោមច្បាប់ជាតិផងដែរ។ ដោយសារសហចៅក្រមស៊ើបអង្កេតមិនបានកំណត់និយមន័យ ឬចង្អុលយោងលើនិយមន័យនៃបទល្មើសក្រោមច្បាប់ជាតិនិងអន្តរជាតិនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងនីតិវិធីមុនៗ វាមិនបង្ហាញឲ្យយើងឃើញច្បាស់ថា តើសហចៅក្រមស៊ើបអង្កេតធ្វើការសន្និដ្ឋាន ដូចដែលបានរៀបរាប់ខាងលើតាមរបៀបណា?

វាក្យខណ្ឌ២៥: អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេត ខកខានមិនបានបង្ហាញហេតុផលចំពោះសេចក្តីសម្រេច ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តឱ្យស្របទៅតាមលក្ខខណ្ឌនៃវិធាន៦៧.៤ នៃវិធានផ្ទៃក្នុងនិងបទបដ្ឋានអន្តរជាតិ ។

វាក្យខណ្ឌ២៦: សហព្រះរាជអាជ្ញាផ្តល់ទឡ្ហីករណ៍ថា បទល្មើសក្រោមច្បាប់ជាតិគឺផ្អែកលើអំពើដូចគ្នា ដូចបទល្មើសក្រោមច្បាប់អន្តរជាតិ ចំពោះវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ដូចដែលបានកំណត់ខាងលើ បទល្មើសក្រោមច្បាប់ជាតិត្រូវតែបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដើម្បីសម្រេចថា តើសហចៅក្រមស៊ើបអង្កេតបានអនុវត្តកិច្ចរបស់ខ្លួនត្រឹមត្រូវដែរឬទេ ដោយមិនធ្វើការបញ្ចូលបទល្មើសក្រោមច្បាប់ជាតិ ។ បន្ថែមលើបទល្មើសអន្តរជាតិដែលបានចោទប្រកាន់ អង្គបុរេជំនុំជម្រះនឹងធ្វើការ

ពិនិត្យថា តើបទល្មើសក្រោមច្បាប់ជាតិ ត្រូវបានច្របាច់បញ្ចូលក្នុងបទល្មើសក្រោម ច្បាប់អន្តរជាតិដែរឬទេ?

វាក្យខណ្ឌ២៧: ដើម្បីសម្រេចថាតើបទល្មើសក្រោមច្បាប់ជាតិត្រូវបានច្របាច់បញ្ចូលក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិ ដែលមានចែងរួចស្រាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យលើបទល្មើសក្រោមច្បាប់ជាតិ មានធាតុផ្សំដែលមិនមាននៅក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិដែរឬទេ?

ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដាបានលើកឡើង ប្រសិនបើបទល្មើសណាមួយទាមទារការបង្ហាញអង្គហេតុមួយដែលបទល្មើសផ្សេងទៀតមិនទាមទារ ធាតុផ្សំអង្គហេតុមួយនេះគឺវាខុសគ្នានឹងធាតុផ្សំអង្គហេតុមួយទៀត។

**ការប្រៀបធៀបធាតុផ្សំនៃបទល្មើស ដែលគេបានបង្កើតឡើង**

វាក្យខណ្ឌ២៨: អង្គបុរេជំនុំជម្រះធ្វើការប្រៀបធៀបធាតុផ្សំសំខាន់ៗនៃបទល្មើសក្រោមច្បាប់ជាតិជាមួយនឹងធាតុផ្សំបទល្មើសអន្តរជាតិដែលត្រូវចោទប្រកាន់ជាលម្អិត។

ក) បទទារុណកម្ម

វាក្យខណ្ឌ២៩: សេចក្តីសន្និដ្ឋានបទល្មើសក្រោមច្បាប់ជាតិ ចំពោះបទទារុណកម្ម។

វាក្យខណ្ឌ៣០: អង្គបុរេជំនុំជម្រះយល់ឃើញថា ធាតុផ្សំអត្ថនោម័តិដំបូងចំពោះនិយមន័យក្រោមច្បាប់ជាតិថា ដើម្បីឱ្យអ្នកនោះឈឺជាខ្លាំង ហើយផ្តាយប្រាប់ព័ត៌មានផ្សេងៗដែលមានប្រយោជន៍ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មដ៏ធ្ងន់ណាមួយក្តី គឺខុសពីនិយមន័យក្រោមច្បាប់អន្តរជាតិ។ និយមន័យក្រោមច្បាប់ជាតិ មិនត្រឹមតែទាមទារឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងគោលបំណងយកព័ត៌មានប៉ុណ្ណោះទេ វាថែមទាំងទាមទារលក្ខខណ្ឌថា ព័ត៌មាននោះចាំបាច់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬមជ្ឈិម។ អង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីកាត់ទោសបុគ្គលណាម្នាក់ពីបទល្មើលក្រោមច្បាប់ជាតិ វានឹងមិនគ្រប់គ្រាន់ឡើយក្នុងការបង្ហាញថាបុគ្គលនោះបានធ្វើទារុណកម្មក្នុងគោលបំណងយកព័ត៌មាន ឬចម្លើយសារភាពដែលធាតុផ្សំនេះ គឺជាលក្ខខណ្ឌកំណត់ក្នុងនិយមន័យក្រោមច្បាប់អន្តរជាតិ។

វាក្យខណ្ឌ៣១: ធាតុផ្សំអត្ថនោម័តិទី២ ដែលជាលក្ខខណ្ឌនៅក្នុងបទល្មើសក្រោមច្បាប់ជាតិ គឺធ្វើទារុណកម្មដើម្បីសងសឹក ធាតុផ្សំនេះមានលក្ខខណ្ឌស្រដៀងគ្នានឹងគោលបំណងនៃការដាក់ទណ្ឌកម្ម

ដែលមានកំណត់ក្នុងនិយមន័យក្រោមច្បាប់អន្តរជាតិ។ នៅពេលដែលយកតែគោលបំណងជាក់លាក់មួយនេះមកពិចារណា ធាតុផ្សំនៃបទល្មើសក្រោមច្បាប់ជាតិនិងអន្តរជាតិគឺ ដូចតែគ្នា។

៣២: ធាតុផ្សំអត្តនោម័តិទី៣ នៃបទល្មើសក្រោមច្បាប់ជាតិ គឺធ្វើទារុណកម្មដោយអំពើចិត្តព្រៃ។ ធាតុផ្សំនេះមិនមានលក្ខខណ្ឌស្មើគ្នាទៅនឹងនិយមន័យក្រោមច្បាប់អន្តរជាតិឡើយ។ ធាតុផ្សំនេះហាក់ដូចជាមានលក្ខណៈទូលាយជាងធាតុផ្សំមួយក្នុងចំណោមធាតុផ្សំទាំងឡាយដែលកំណត់នៅក្នុងនិយមន័យក្រោមច្បាប់អន្តរជាតិ។

វាក្យខណ្ឌ៣៣: អង្គបុរេជំនុំជម្រះសន្និដ្ឋានថា និយមន័យនៃទារុណកម្មដែលបានលើកឡើងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មានធាតុផ្សំអត្តនោម័តិចំនួន២ដែលមិនបានបញ្ចូលនៅក្នុងនិយមន័យក្រោមច្បាប់អន្តរជាតិ។ ធាតុផ្សំនោះគឺ គោលបំណងនៃការធ្វើទារុណកម្មដើម្បីឱ្យឈឺចាប់ ឱ្យឈឺជាខ្លាំង ហើយផ្តល់ព័ត៌មានផ្សេងៗ ដែលមានប្រយោជន៍ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬមជ្ឈិមណាមួយក្តី និងការធ្វើទារុណកម្មដោយអំពើចិត្តព្រៃ។

ខ) បទមនុស្សឃាត

វាក្យខណ្ឌ៣៤: សេចក្តីសន្និដ្ឋាននៃអង្គបុរេជំនុំជម្រះលើបទល្មើសក្រោមច្បាប់ជាតិ ចំពោះបទមនុស្សឃាត និងបទមនុស្សឃាតដោយគិតទុកជាមុន។

វាក្យខណ្ឌ៣៥: ចេតនាត្រឹមត្រូវឱ្យតតិយជនឈឺ ដោយមិនមានបំណងធ្វើឱ្យស្លាប់ គឺគ្រាប់គ្រាន់ក្នុងការរកពិរុទ្ធភាពរបស់បុគ្គលម្នាក់ចំពោះបទមនុស្សឃាត អនុលោមតាមមាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែ បទល្មើសក្រោមច្បាប់អន្តរជាតិទាមទារឱ្យមានចេតនាធ្វើឱ្យស្លាប់ ឬធ្វើឱ្យមានការខូចខាតធ្ងន់ធ្ងរលើរូបកាយ ឬបង្កព្យសនកម្មធ្ងន់ធ្ងរ ។ ដូច្នេះ បទល្មើសក្រោមច្បាប់ជាតិទាមទារធាតុផ្សំអត្តនោម័តិមួយ ដែលមានទម្រង់ស្រាលជាងចំពោះចេតនាដែលជាលក្ខខណ្ឌនៅក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិ។ វាមិនទាមទារឱ្យមានការបង្ហាញអង្គហេតុ ដែលមិនមែនជាលក្ខខណ្ឌនៅក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិ ។ ដូច្នេះ វាមិនចាំបាច់ឱ្យអង្គបុរេជំនុំជម្រះ ធ្វើការពិចារណាបទមនុស្សឃាតដោយមិនមានចេតនាធ្វើឱ្យស្លាប់ ដូចដែលមានចែងនៅក្នុងមាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌ ដើម្បីដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ ពីព្រោះតែបទល្មើសនេះបានបញ្ចូលក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិដែលមានចែងរួចហើយក្នុងដីកានោះ។

វាក្យខណ្ឌ៣៦: បទមនុស្សឃាតគិតទុកជាមុន ។ អនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

ទាមទារធាតុផ្សំជាក់លាក់ចំពោះការគិតទុកជាមុន ដែលធាតុផ្សំនេះមិនទាមទារនៅក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិឡើយ ហើយបទល្មើសនេះក៏ទាមទារនូវធាតុផ្សំចេតនាធ្វើឱ្យស្លាប់ផងដែរ។ ប៉ុន្តែ ធាតុផ្សំនូវចេតនាធ្វើឱ្យស្លាប់ ឬធ្វើឱ្យមានការខូចខាតធ្ងន់ធ្ងរលើរូបកាយ ឬបង្កព្យសនកម្មធ្ងន់ធ្ងរដោយដឹងច្បាស់ថាការវាយប្រហារនោះនឹងនាំដល់ស្លាប់។ ធាតុផ្សំគ្រប់គ្រាន់ក្នុងការកំណត់ពិរុទ្ធភាព អនុលោមតាមបទល្មើសក្រោមច្បាប់អន្តរជាតិ។

**បទចោទត្រួត**

វាក្យខណ្ឌ៣៧: ដោយរកឃើញថា បទទារុណកម្មនិងបទមនុស្សឃាតគិតទុកជាមុនក្រោមច្បាប់ជាតិ មិនត្រូវរួមបញ្ចូលបទល្មើសក្រោមច្បាប់អន្តរជាតិ អង្គបុរេជំនុំជម្រះនៅពេលនេះនឹងធ្វើការពិនិត្យថាតើបទល្មើសទាំងពីរនេះ តាមផ្លូវច្បាប់អាចបញ្ចូលក្នុងដីកាបញ្ជូនទៅជំនុំជម្រះដែរឬទេ? ពីព្រោះតែបទល្មើសទាំងពីរនេះ បានផ្អែកលើអង្គហេតុដូចគ្នា ដូចបទល្មើសក្រោមច្បាប់អន្តរជាតិដែរ ដែលមានចែងស្រាប់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

វាក្យខណ្ឌ៣៨: អង្គបុរេជំនុំជម្រះសង្កេតឃើញថា ទាំងវិធានផ្ទៃក្នុង ទាំងច្បាប់កម្ពុជា មិនមានបទប្បញ្ញត្តិចែងពាក់ព័ន្ធនឹងលទ្ធភាពក្នុងការចែងបទចោទផ្សេងៗគ្នា ចំពោះអំពើដូចគ្នានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដូច្នេះ ដូចមានចែងនៅក្នុងមាត្រា១២ នៃកិច្ចព្រមព្រៀង អង្គបុរេជំនុំជម្រះនឹងស្វែងរកបទដ្ឋានណែនាំចំពោះវិធាននីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិ។

វាក្យខណ្ឌ៣៩: យុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិពិសេសចែងថា នៅក្នុងដំណើរការក្តីព្រហ្មទណ្ឌអន្តរជាតិ គេអនុញ្ញាតឱ្យបញ្ចូលបទចោទខុសៗគ្នាចំពោះអំពើតែមួយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាំងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ទាំងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា មានយុត្តិសាស្ត្រជាច្រើនដែលគាំទ្រចំពោះការអនុវត្តលើការចោទត្រួត តុលាការពិសេសប្រទេសសេរ៉ាឡេអូន ក៏បានប្រកាន់យកការអនុវត្តបែបនេះដែរ។ គេសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតបានបញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចំពោះអំពើដូចគ្នា។

វាក្យខណ្ឌ៤០: អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការបញ្ចូលបទចោទលើសពីមួយចំពោះអំពើដូចគ្នានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានប៉ះពាល់ដល់គោលការណ៍គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង ពីព្រោះវាមិនពាក់ព័ន្ធនឹងការកំណត់ជាក់លាក់លើការទទួលខុសត្រូវ ការដាក់ទោស

ទណ្ឌកម្ម ។

**ការដាក់ទោសទណ្ឌកម្មលើបទល្មើសក្រោមច្បាប់ជាតិដែលនៅតែបន្តមានអាទិភាព**

វាក្យខណ្ឌ៤១: ដោយសារជាបញ្ហាបន្ថែមមួយទៀត អង្គបុរេជំនុំជម្រះត្រូវធ្វើការពិចារណាដើម្បីចោទប្រកាន់ថាតើបទទារុណកម្មនិងបទមនុស្សឃាត ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅអាចផ្តន្ទាទោសបាននៅពេលនេះដែរឬទេ?

បន្ទាប់ពីការវិភាគអង្គបុរេជំនុំជម្រះសន្និដ្ឋានដូចនេះដែរ។

**មូលដ្ឋានអង្គហេតុចំពោះបទល្មើសក្រោមច្បាប់ជាតិ**

វាក្យខណ្ឌ៤២: អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះដរាបណាមានការបញ្ចូលនូវបទទារុណកម្មនិងបទមនុស្សឃាតក្រោមច្បាប់ជាតិ ពីព្រោះការធ្វើការកែប្រែណាមួយ ចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានកំណត់ដោយវិសាលភាពនៃបណ្តឹងឧទ្ធរណ៍និងមូលដ្ឋានដូចមានរៀបរាប់នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍។ ដោយសារធាតុផ្សំនៃបទឧក្រិដ្ឋក្រោមច្បាប់ជាតិ មានលក្ខណៈខុសគ្នាពីធាតុផ្សំក្រោមច្បាប់អន្តរជាតិ អង្គបុរេជំនុំជម្រះនឹងផ្តល់ហេតុផលរបស់ខ្លួននៅក្នុងសេចក្តីសម្រេច ក្នុងករណីដែលទម្រង់នៃការទទួលខុសត្រូវ មិនមានភស្តុតាងគាំទ្រគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ជនត្រូវចោទ។

វាក្យខណ្ឌ៤៣: ដូច្នេះអង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសមស្រប ហើយអាចធ្វើទៅបានក្នុងការចែងបទទារុណកម្ម និងឃាតកម្មគិតទុកជាមុនក្រោមច្បាប់ជាតិ បញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើមានភស្តុតាងបញ្ជាក់ត្រឹមត្រូវ ពីព្រោះតែបទល្មើសទាំងពីរនេះ មានធាតុផ្សំដែលមិនមានបញ្ចូលនៅក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិ ហើយនៅតែអាចផ្តន្ទាទោសបាននៅពេលបច្ចុប្បន្ននេះ។ ការធ្វើដូច្នេះនឹងធានាដល់ការគោរពសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជូនដំណឹងអំពីប្រភេទនិងសំអាងនៃបទចោទដែលដាក់បន្ទុកលើខ្លួន និងសិទ្ធិទទួលបានពេលវេលា និងសម្ភារៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន ដូចមានចែងក្នុងមាត្រា៣៥ (ថ្មី) នៃច្បាប់ អ.វ.ត.ក។

វាក្យខណ្ឌ៤៤: អង្គបុរេជំនុំជម្រះអាចបញ្ចូលបទទារុណកម្មនិងបទឃាតកម្មគិតទុកជាមុន អនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដរាបណាអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលជាផ្នែកមួយនៃកិច្ចស៊ើបសួរ គ្រប់គ្រាន់ក្នុងការដាក់បញ្ចូល។ ដោយសារសហចៅក្រមស៊ើបអង្កេតមិនមានផ្តល់ហេតុផលចំពោះសេចក្តីសន្និដ្ឋានរបស់ខ្លួនថា អំពើមួយចំនួនដែលបានកំណត់ក្នុងកិច្ចស៊ើបសួរ ក៏

បានបង្កើតជាបទល្មើសក្រោមច្បាប់ជាតិ ដូច្នេះលក្ខខណ្ឌតម្រូវនោះ គឺត្រូវធ្វើការពិនិត្យថាតើអំពើទាំងឡាយដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គ្រប់គ្រាន់ក្នុងការបញ្ជូនជនត្រូវត្រូវចោទទៅជំនុំជម្រះចំពោះបទល្មើទាំងនោះដែរឬទេ?

**បទទារុណកម្ម**

វាក្យខណ្ឌ៩៨: អង្គបុរេជំនុំជម្រះយល់ឃើញថា មានមូលដ្ឋានអង្គហេតុគ្រប់គ្រាន់ក្នុងការចោទប្រកាន់ជនត្រូវចោទ ក្រោមទម្រង់នៃការទទួលខុសត្រូវលើការរៀបចំផែនការ ការបង្គាប់បញ្ជា ការញុះញង់ និងការជួយ និងទំនុកបម្រុង និងការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះទារុណកម្មដែលអ្នកនៅក្រោមបង្គាប់របស់ ឌុច បានប្រព្រឹត្តលើអ្នកទោសក្នុងគោលបំណងធ្វើឱ្យឈឺជាខ្លាំង ហើយផ្តល់ប្រាប់ព័ត៌មានផ្សេងៗដែលមានប្រយោជន៍ដល់ការប្រព្រឹត្តិបទល្មើសដទៃទៀត។ អំពើទាំងនេះត្រូវបានកំណត់តាមច្បាប់ថា បទទារុណកម្ម អនុលោមតាមមាត្រា៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយអាចផ្តន្ទាទោសបានតាមមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក។

វាក្យខណ្ឌ៩៩: វាក្យខណ្ឌទី៩០ ដល់វាក្យខណ្ឌទី៩៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ រៀបរាប់ពីភស្តុតាងដែលលើកឡើងថា ឌុច បានប្រព្រឹត្តទារុណកម្មដូចមានផ្ទុះបញ្ចាំងក្នុងបទចោទ ចំពោះអង្គហេតុនៅក្នុងវាក្យខណ្ឌទី១៥៣ អង្គបុរេជំនុំជម្រះមិនបានកំណត់អង្គហេតុជាក់លាក់ចេញពីវាក្យខណ្ឌទាំងនេះ ដែលអាចអនុញ្ញាតចំពោះការចោទប្រកាន់លើការប្រព្រឹត្តិបទទារុណកម្មក្រោមច្បាប់ជាតិ។ ដូច្នេះទម្រង់នៃការទទួលខុសត្រូវមិនបានដាក់បញ្ចូល។

វាក្យខណ្ឌ១០០: អង្គបុរេជំនុំជម្រះរកឃើញថា មិនមានភស្តុតាងគ្រប់គ្រាន់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបញ្ជាក់ថាទារុណកម្មបានធ្វើឱ្យ ដោយអំពើចិត្តព្រៃ ដើម្បីអាចឱ្យអង្គបុរេជំនុំជម្រះអាចបញ្ចូលធាតុផ្សំនៃបទល្មើសក្រោមច្បាប់ជាតិនៅក្នុងបទចោទ។

ខ) មនុស្សឃាតគិតទុកជាមុន

វាក្យខណ្ឌ១០២: អង្គបុរេជំនុំជម្រះយល់ឃើញថា មានមូលដ្ឋានអង្គហេតុគ្រប់គ្រាន់ក្នុងការចោទប្រកាន់ជនត្រូវចោទក្រោមទម្រង់នៃការទទួលខុសត្រូវលើការរៀបចំផែនការ ការបង្គាប់បញ្ជា ការញុះ-ញង់ និងការជួយ និងទំនុកបម្រុង និងការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះបទមនុស្សឃាតគិតទុកជាមុន ដែលបានប្រព្រឹត្តឡើងដោយបុគ្គលិកក្រោមបង្គាប់របស់ខ្លួននៅមន្ទីរស-២១ រួមទាំងនៅជើងឯក។ អង្គហេតុទាំងនេះត្រូវបានគេកំណត់តាមផ្លូវច្បាប់ថាជាបទមនុស្សឃាតគិតទុកជាមុន អនុលោមតាម

មាត្រា៥០១ និងមាត្រា៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយផ្តន្ទាទោសតាមមាត្រា៣(ថ្មី) នៃច្បាប់ អ.វ.ត.ក។

វាក្យខណ្ឌ៥០៣: បទទារុណកម្ម និងបទមនុស្សឃាតគិតទុកជាមុន អនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនមាននៅក្នុងចំណោមបទចោទដែលសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ជនត្រូវចោទ នៅពេលចូលខ្លួនដំបូង ឬក្នុងដំណាក់កាលក្រោយៗមកទៀត។

វាក្យខណ្ឌ១០៤: អង្គហេតុគាំទ្រធាតុផ្សំដែលបានបង្កើតឡើងជាក់លាក់ ចំពោះបទល្មើសក្រោមច្បាប់ជាតិត្រូវបានបញ្ចូលក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ដោយសារអង្គហេតុទាំងនេះ ត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចំពោះធាតុផ្សំជាក់លាក់លើបទទារុណកម្មក្រោមច្បាប់ជាតិធ្វើទារុណកម្មដើម្បីឱ្យឈឺជាខ្លាំង ហើយផ្តាយប្រាប់ព័ត៌មានផ្សេងៗ ដែលមានប្រយោជន៍ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬមជ្ឈិមណាមួយក្តី ។

អង្គបុរេជំនុំជម្រះចង្អុលយោងជាក់លាក់ លើវាក្យខណ្ឌទី៥២ វាក្យខណ្ឌទី១១០ និងវាក្យខណ្ឌទី១១២ (ឆ) នៃវាក្យខណ្ឌទី១១៣ (ក) នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ។ ចំពោះធាតុផ្សំជាក់លាក់លើបទមនុស្សឃាតគិតទុកជាមុន ក្រោមច្បាប់ជាតិ ចេតនាធ្វើឱ្យស្លាប់ និងការគិតទុកជាមុន អង្គបុរេជំនុំជម្រះ យោងលើវាក្យខណ្ឌទី៥៤ ទី៥៥ វាក្យខណ្ឌទី១០៨ និងទី១១៣(ខ) នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។

វាក្យខណ្ឌ១០៥: វិធានផ្ទៃក្នុងមើលឃើញច្បាស់អំពីលទ្ធភាពដែលថា ការកំណត់បទចោទអាចមានការប្រែប្រួលសូម្បីក្នុងដំណាក់កាលជំនុំជម្រះលើអង្គសេចក្តី ។ ការបន្ថែមបទចោទនៅក្នុងដំណាក់កាលនេះ មិនបានប៉ះពាល់សិទ្ធិដល់ជនត្រូវចោទក្នុងការទទួលបានការជូនដំណឹងអំពីបទចោទដូចមានចែងក្នុងមាត្រា៣៥(ថ្មី)នៃច្បាប់ អ.វ.ត.ក. ដោយសារជនត្រូវចោទអាននឹងមានឱកាសការពារខ្លួនចំពោះបទល្មើសជាក់លាក់ទាំងនេះ ក្នុងអំឡុងពេលជំនុំជម្រះលើអង្គសេចក្តី ។

វាក្យខណ្ឌ១០៦: ដូច្នេះអង្គបុរេជំនុំជម្រះយល់ឃើញថា បទទារុណកម្មនិងបទមនុស្សឃាតគិតទុកជាមុន ក្រោមច្បាប់ជាតិអាចបន្ថែមនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ។

V. មូលដ្ឋានទី២: ការខកខានក្នុងការដាក់បញ្ចូលសហឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវមួយប្រភេទ

ក) សេចក្តីសន្និដ្ឋានរបស់ភាគី

វាក្យខណ្ឌ៥៣: នៅក្នុងមូលដ្ឋានទី២ នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាផ្តល់ទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់មួយ នៅពេលដែលខ្លួនខកខានមិនបានចោទប្រកាន់ ឌុច ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈការចូលរួមប្រព្រឹត្តនៅក្នុងសហឧក្រិដ្ឋកម្មរួម ។ ទោះបីជាទម្រង់នៃការទទួលខុសត្រូវមួយបែបនេះ បានលាតត្រដាងទាំងស្រុងតាមរយៈអង្គហេតុ ដូចបានរកឃើញក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ។

វាក្យខណ្ឌ៥៤: អង្គបុរេជំនុំជម្រះធ្វើការសង្ខេបសេចក្តីសន្និដ្ឋានរបស់ភាគី ។

វាក្យខណ្ឌ៥៥: សហព្រះរាជអាជ្ញាស្នើឡើងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះគួរតែធ្វើការកែប្រែ ដោយយកវាក្យខណ្ឌដែលបានស្នើឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍មកជំនួសនឹងវាក្យខណ្ឌទី១៥៣។

វាក្យខណ្ឌ៥៦: សហមេធាវីការពារក្តី មិនធ្វើការឆ្លើយតបជាក់លាក់ទៅនឹងទឡ្ហីករណ៍លើកំហុសអង្គច្បាប់ ចំពោះសហឧក្រិដ្ឋកម្មរួម ដែលសហព្រះរាជអាជ្ញាបានដាក់ជូនឡើយ។

វាក្យខណ្ឌ៥៧: នៅក្នុងសារណាតប ចំពោះសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី សហមេធាវីការពារក្តីសន្និដ្ឋានថា មូលដ្ឋានសម្រាប់ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម និងហេតុផលដែលលើកឡើងដោយសហព្រះរាជអាជ្ញានៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ ដើម្បីបញ្ចូលបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនមានមូលដ្ឋានឡើយ ។ ដោយសារ ឌុច និងបុគ្គលិកក្រោមឱវាទរបស់គាត់បានបញ្ជាក់យ៉ាងច្បាស់ជូនដល់សហចៅក្រមស៊ើបអង្កេត អំពីលក្ខណៈនៃតួនាទីរបស់ពួកគេនិងការចូលរួមផ្សេងៗគ្នានៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅស-២១ ។ សហមេធាវីការពារក្តីផ្តល់អំណះអំណាងបន្តទៀតថា សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី បានលាតត្រដាងមន្ទិលសង្ស័យពាក់ព័ន្ធនឹងលទ្ធភាពនៃការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនៅអ.វ.ត.ក. ដែលជាទ្រឹស្តី ដែលថាទ្រឹស្តីនេះមិនបានរំលោភបំពានលើគោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង ។ ហើយសហមេធាវីការពារក្តីលើកឡើងថា ប្រភេទទី២និងប្រភេទទី៣ ជាការពិតណាស់ គឺមានភាពចម្រូងចម្រាស់ ។

នៅក្នុងចំណុចចុងក្រោយ សហមេធាវីការពារក្តីលើកឡើងថា ប្រសិនបើអង្គបុរេជំនុំជម្រះរកឃើញថាទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួមយកមកអនុវត្តនៅ អ.វ.ត.ក បញ្ហាចោទលើការទទួលខុសត្រូវរបស់ ឌុច ក្រោមទម្រង់នៃការទទួលខុសត្រូវមួយនេះ គួរតែយកទៅដោះស្រាយនៅក្នុងដំណាក់កាលជំនុំជម្រះលើអង្គសេចក្តី ។

ខ) សេចក្តីពិចារណា

វាក្យខណ្ឌ១១២: អនុលោមតាមលក្ខខណ្ឌតម្រូវនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គបុរេជំនុំជម្រះត្រូវពិនិត្យមើលបញ្ហាសហឧក្រិដ្ឋកម្មរួមនៅក្នុងដំណាក់កាលនេះ ជាជាងទុកវាចោលហើយបង្កើតជាបញ្ហាដល់អង្គជំនុំជម្រះសាលាដំបូង ។

វាក្យខណ្ឌ៥៩: អនុលោមតាមវិធាន៦៧.២ នៃវិធានផ្ទៃក្នុង ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវចែងអំពីអត្តសញ្ញាណរបស់ជនត្រូវចោទ ការរៀបរាប់អំពីអង្គហេតុ និងបទចោទដែលសហចៅក្រមស៊ើបអង្កេតបានកំណត់ ដោយរួមទាំងបទប្បញ្ញត្តិព្រហ្មទណ្ឌដែលពាក់ព័ន្ធនិងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ។ សហឧក្រិដ្ឋកម្មរួមដែលជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ទាមទារឱ្យមានការចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដូច្នេះ អង្គបុរេជំនុំជម្រះត្រូវពិនិត្យមើលបញ្ហាសហឧក្រិដ្ឋកម្មរួមនៅក្នុងដំណាក់កាលនេះ ជាជាងទុកវាចោលហើយបង្កើតជាបញ្ហានៅសាលាដំបូង ។

វាក្យខណ្ឌ៦០: ចំពោះមូលដ្ឋាននៃទឡ្ហីករណ៍ដែលសហព្រះរាជអាជ្ញាលើកឡើង អង្គបុរេជំនុំជម្រះបានអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តី ឱ្យដាក់សារណាដើម្បីផ្តល់ព័ត៌មានដល់អង្គបុរេជំនុំជម្រះឱ្យបានគ្រប់គ្រាន់លើទស្សនទាននៃសហឧក្រិដ្ឋកម្មរួម ។ ព័ត៌មានដែលទទួលបាន គឺជាត្រីវិស័យដឹកនាំអង្គបុរេជំនុំជម្រះឱ្យធ្វើការសិក្សាកាន់តែពិស្តារ លើវិសាលភាពនៃការស៊ើបអង្កេតចំពោះទម្រង់នៃការទទួលខុសត្រូវផ្សេងៗដែលអាចមាន ។

អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ទទួលស្គាល់ភាពខុសគ្នារវាងការប្រព្រឹត្តិរួមគ្នានិងការផ្សំគំនិត ដែលចំណុចនេះនៅជាធរមាន ។ នៅក្នុងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី យើងសង្កេតឃើញថាសហឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវមួយប្រភេទក្នុងការរៀបរាប់ពីស្ថានភាពអង្គហេតុដែលឧក្រិដ្ឋកម្មបានប្រព្រឹត្តរួមគ្នាដោយចារីពីរនាក់ ឬច្រើនជាងនេះ ។

អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសង្កេតនេះគឺស្របជាមួយឯកសារបោះពុម្ពផ្សាយលើបញ្ហានេះ ចំណុចនេះវាពាក់ព័ន្ធក្នុងការសម្រេចថា--

តើអាចឱ្យខ្ញុំបន្តទៀតទេ? ខ្ញុំសូមចាប់ផ្តើមអានពីវាក្យខណ្ឌ៦០ ឡើងវិញ។ ចំពោះមូលដ្ឋាននៃទឡ្ហីករណ៍ដែលសហព្រះរាជអាជ្ញាលើកឡើង ។ អង្គបុរេជំនុំជម្រះបានអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តីឱ្យដាក់សារណា ដើម្បីផ្តល់ព័ត៌មានដល់អង្គបុរេជំនុំជម្រះឱ្យបានគ្រប់គ្រាន់លើទស្សនទាននៃសហឧក្រិដ្ឋកម្មរួម។ ព័ត៌មានដែលទទួលបាន គឺជាត្រីវិស័យដឹកនាំអង្គបុរេជំនុំជម្រះឱ្យធ្វើការសិក្សាកាន់

តែពិស្តារលើវិសាលភាពនៃការស៊ើបអង្កេត ចំពោះទម្រង់នៃការទទួលខុសត្រូវផ្សេងៗដែលអាចមាន ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ទទួលស្គាល់ភាពខុសគ្នារវាងការប្រព្រឹត្តិរួមគ្នា និងការផ្សំគំនិតដែលចំណុចនេះនៅជាធរមាន ។

នៅក្នុងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី យើងសង្កេតឃើញថា សហឧក្រិដ្ឋកម្មរួម គឺទំនងជាទម្រង់នៃការទទួលខុសត្រូវមួយប្រភេទក្នុងការរៀបរាប់ពីស្ថានភាពអង្គហេតុដែលឧក្រិដ្ឋកម្មបានប្រព្រឹត្តរួមគ្នាដោយចារីពីរនាក់ ឬក៏ច្រើនជាងនេះ ។ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសង្កេតនេះគឺស្របជាមួយនឹងឯកសារបោះពុម្ពផ្សាយលើបញ្ហានេះ ។ចំណុចនេះវាពាក់ព័ន្ធក្នុងការសម្រេចថាតើទម្រង់នៃការទទួលខុសត្រូវមួយនេះអាចយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក ដែរឬទេ? ហើយទម្រង់មួយនេះអាចមានឥទ្ធិពលលើការសិក្សា វិនិច្ឆ័យលើវិសាលភាពនៃការស៊ើបអង្កេតដែរឬទេ?

វាក្យខណ្ឌ៦១: យោងតាមលក្ខខណ្ឌនៅក្នុងវិធាន៦៧.៤ នៃវិធានផ្ទៃក្នុង ដីកាដំណោះស្រាយត្រូវតែផ្តល់ហេតុផល ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេត ខកខានក្នុងការផ្តល់ហេតុផល ថាតើហេតុអ្វីបានជាបដិសេធចោលសំណើរបស់សហព្រះរាជអាជ្ញា? ស្នើសុំបញ្ចូលការចោទលើសហឧក្រិដ្ឋកម្មរួម ដែលបានប្រព្រឹត្តឡើងនៅក្នុងក្របខ័ណ្ឌស-២១ ។ ម៉្យាងទៀត ចំពោះទម្រង់នៃការទទួលខុសត្រូវនានា សហចៅក្រមស៊ើបអង្កេតមិនបានពន្យល់ការកំណត់បទចោទដែលខ្លួនជ្រើសរើស ។

វាក្យខណ្ឌ៦២: អង្គបុរេជំនុំជម្រះយោងលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាបំបែករឿងក្តីចំពោះការចោទប្រកាន់សហឧក្រិដ្ឋកម្មរួម ។

**សេចក្តីសន្និដ្ឋានលើការស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០១**

វាក្យខណ្ឌ៦៣: នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីនានានិងមេធាវីរបស់ពួកគេ ។ អនុលោមតាមវិធាន៦៦.១នៃវិធានផ្ទៃក្នុង ដោយជម្រាបថាសហចៅក្រមស៊ើបអង្កេត បានបញ្ចប់កិច្ចស៊ើបសួរចំពោះសំណុំរឿងលេខ០០១ ។

វាក្យខណ្ឌ៦៤: សកម្មភាពនិងសមាជិកភាពនៃគណៈមន្ទីរស-២១ និងដំណាក់កាលរៀបចំផែនការបង្កើតស-២១ ត្រូវបានស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០១ ។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតមិនបានចង្អុលបញ្ជាក់ប្រាប់សហព្រះរាជអាជ្ញា នៅដំណាក់កាលណាមួយអំពីអង្គហេតុទាំងនេះថាជាអង្គហេតុថ្មីដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មរួម ឬសហឧក្រិដ្ឋកម្មរួមឡើយអនុលោមតាមវិធាន៥៥.៣

នៃវិធានផ្ទៃក្នុង។ ជាលទ្ធផលមិនមានការផ្តួចផ្តើមចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំពោះការប្រព្រឹត្តិរួម ឬសហឧក្រិដ្ឋកម្មរួម ដែលកើតឡើងនៅស-២១ ហើយមិនមានសំណើធ្វើឡើងដើម្បីសុំការស៊ើបសួរបន្ថែមចំពោះទម្រង់នៃការទទួលខុសត្រូវទាំងនេះឡើយ ។ ដូច្នេះ ទោះបីអង្គហេតុដូចដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លាតត្រដាងលទ្ធភាពចំពោះប្រភេទនៃការប្រព្រឹត្តិរួមដែលពាក់ព័ន្ធនឹងអំពើទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរស-២១ក៏ដោយ ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ទម្រង់នៃការទទួលខុសត្រូវមួយនេះមិនមែនជាផ្នែកជាក់លាក់មួយនៃការស៊ើបសួរឡើយ ។

**ដីកាសន្និដ្ឋានស្ថាពរ**

វាក្យខណ្ឌ១២៣: បន្ទាប់ពីបញ្ចប់ការស៊ើបសួរលើសំណុំរឿងលេខ០០១ សហព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានស្ថាពរ ។ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា គឺជាសំណើដែលមានសំអាងហេតុ ដើម្បីចោទប្រកាន់បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ដោយផ្អែកលើការបញ្ចប់ការស៊ើបសួរ ។

វាក្យខណ្ឌ១២៤: សហព្រះរាជអាជ្ញាលើកអំណះអំណាងនៅក្នុងដីកាសន្និដ្ឋានស្ថាពរថា ភស្តុតាងនៅក្នុងសំណុំរឿងនិងភស្តុតាងដែលយោងនៅក្នុងផ្នែកអង្គហេតុនៅក្នុងដីកាសន្និដ្ឋានស្ថាពរបង្កើតឡើងថា ឌុច បានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងនាមជាអ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ។

វាក្យខណ្ឌ១២៥: ចាប់ផ្តើមនៅក្នុងវាក្យខណ្ឌទី២៤១ នៃដីកាសន្និដ្ឋានស្ថាពរ សហព្រះរាជអាជ្ញាលើកពិភាក្សាអំពីការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមថា ការទទួលខុសត្រូវនេះអាចអនុវត្តចំពោះឌុច នៅក្នុងក្របខណ្ឌនៃមន្ទីរស-២១ ។ នៅក្នុងវាក្យខណ្ឌទី២៥០ និងវាក្យខណ្ឌទី២៥១ សហព្រះរាជអាជ្ញាបានបញ្ជាក់អំពីប្រភេទនៃសហឧក្រិដ្ឋកម្មរួម ដែលបានចោទប្រកាន់ដែលចាប់ពីពេលនេះទៅហៅថាសហឧក្រិដ្ឋកម្មរួមនៅមន្ទីរស-២១ ។ សហឧក្រិដ្ឋកម្មរួមមានអត្ថិភាពចាប់តាំងពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ នៅពេលដែល សុន សេន បានណែនាំទៅ ណាត និង ឌុច ឱ្យរៀបចំបង្កើតមន្ទីរស-២១ ។ សហឧក្រិដ្ឋកម្មរួមមានអត្ថិភាពចាប់តាំងពីមន្ទីរស-២១ បានដំណើរការទាំងស្រុងនៅខែតុលា ឆ្នាំ១៩៧៥ យ៉ាងហោចណាស់រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ។

គោលបំណងនៃសហឧក្រិដ្ឋកម្មរួម គឺការចាប់ខ្លួន ការឃុំឃាំង ប្រព្រឹត្តអំពើឃោរឃៅ ការសួរចម្លើយ ការធ្វើទារុណកម្ម និងការកម្ទេចចោលក្នុងលក្ខណៈជាលក្ខណៈប្រព័ន្ធចំពោះខ្មាំងទាំងអស់របស់របបកម្ពុជាប្រជាធិបតេយ្យ ។ តាមរយៈការប្រព្រឹត្តិនៅអំពើឧក្រិដ្ឋកម្មផ្សេងៗ ដូចបានរៀបរាប់នៅក្នុង

ដីកាសន្និដ្ឋានស្ថាពរនេះស្រាប់ ។ ប្រព័ន្ធនៃការគាបសង្កត់ដែលបានរៀបចំឡើងកើតមាននៅមន្ទីរស-២១ ចាប់តាំងពីពេលកកើតនៃសហឧក្រិដ្ឋកម្មរួមរហូតដល់ចុងបញ្ចប់របស់វា ។ រាល់ឧក្រិដ្ឋកម្មទាំងអស់ដែលបានកើតឡើងនៅមន្ទីរស-២១ ដូចដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរនេះគឺសុទ្ធតែស្ថិតនៅក្នុងគោលបំណងនៃសហឧក្រិដ្ឋកម្មរួមនេះ ។

ឌុច បានចូលរួមប្រព្រឹត្តនៅក្នុងទូទាំងអំឡុងពេលដែលសហឧក្រិដ្ឋកម្មរួមនេះមានអត្ថិភាពរួមគ្នាជាមួយនឹងអ្នកចូលរួមដទៃទៀតនៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ ដែលពួកគេទាំងនោះបានចូលរួមនៅក្នុងរយៈពេលខុសៗគ្នា ដោយរាប់បញ្ចូលទាំងអតីតលេខានៃមន្ទីរស-២១ ឈ្មោះ ណាត និងសមាជិក សមាជិកាដទៃទៀតនៃគណៈកម្មាធិការមន្ទីរស-២១ ពោលគឺ ឃឹម វ៉ាត ហៅ ហ៊ី និង ហ៊ុយ ស្រែ ព្រមទាំងអ្នកនៅក្រោមបង្គាប់របស់ពួកគេផងដែរ ។

វាក្យខណ្ឌ១២៦: នៅក្នុងសេចក្តីសន្និដ្ឋានតបចំពោះដីកាសន្និដ្ឋានស្ថាពរ សហមេធាវីការពារក្តីរបស់ជនត្រូវចោទលើកទឡ្ហីករណ៍ថា សហព្រះរាជអាជ្ញាបានបញ្ចូលនៅក្នុងដីកាសន្និដ្ឋានស្ថាពរ នូវអង្គហេតុដែលមិនបានបង្កើតឡើងនៅក្នុងពេលស៊ើបសួរ។ ទោះបីជាការអះអាងនេះមិនបានភ្ជាប់ទៅនឹងការចោទប្រកាន់ចំពោះសហឧក្រិដ្ឋកម្មរួមនៅមន្ទីរស-២១ ហើយអង្គហេតុបន្ថែមនោះមិនបានកំណត់ឱ្យបានច្បាស់លាស់ក៏ដោយ។ ទោះបីជាយ៉ាងនេះក៏ដោយ សហមេធាវីការពារក្តីធ្វើការតវ៉ាលើភាពស៊ីជម្រៅនៃការដឹងឮអំពីវិសាលភាពនៃប្រព័ន្ធឧក្រិដ្ឋនៅមន្ទីរស-២១ ដែលគេចោទចំពោះ ឌុច ។

VI. មូលដ្ឋានអង្គហេតុសម្រាប់សហឧក្រិដ្ឋកម្មរួមនៅមន្ទីរស-២១

វាក្យខណ្ឌ១២៧: នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមមានអង្គហេតុទាំងអស់ ដែលចាំបាច់ក្នុងការបញ្ជូន ឌុច ទៅជំនុំជម្រះចំពោះការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួមនៅមន្ទីរស-២១។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតត្រូវឱ្យចោទប្រកាន់ ឌុច ចំពោះការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម ។ សហព្រះរាជអាជ្ញាមិនស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការពិនិត្យរកអង្គហេតុថ្មីៗឡើយ ពីព្រោះធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួមបានរៀបរាប់ត្រង់ៗតែម្តងនៅក្នុងការរកឃើញអង្គហេតុនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

វាក្យខណ្ឌ១២៨: អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហឧក្រិដ្ឋកម្មរួមដែលបានចោទប្រកាន់ហើយពាក់ព័ន្ធនឹង សុន សេន, ណាត , ឃឹម វ៉ាត ហៅ ហ៊ី និង ហ៊ុយ មិនបានបង្កើតជាផ្នែកមួយនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ ដោយសារអវត្តមាននៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម

បញ្ហាចោទបានលើកឡើងថា តើសហឧក្រិដ្ឋកម្មរួមនៅស-២១ បានបង្កើតជាផ្នែកមួយនៃមូលដ្ឋានអង្គហេតុសម្រាប់ការស៊ើបសួរដែរឬទេ? ដើម្បីឆ្លើយតបនឹងបញ្ហានេះ វាជាការចាំបាច់ក្នុងការគូសបញ្ជាក់ខ្លីៗ អំពីធាតុផ្សំអង្គច្បាប់ចំពោះការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម ។

វាក្យខណ្ឌ៧១: អង្គបុរេជំនុំជម្រះធ្វើការគូសបញ្ជាក់ដូចនេះ ។

វាក្យខណ្ឌ៧២: ដោយមើលលើបរិបទនៃធាតុផ្សំ លើការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម អង្គបុរេជំនុំជម្រះយល់ឃើញថា ការបង្កើតសហឧក្រិដ្ឋកម្មរួមនៅមន្ទីរស-២១ ដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងវាក្យខណ្ឌទី៧២ នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍មានលក្ខណៈស្រពិចស្រពិល ។ ជាពិសេស ដោយសារវាពាក់ព័ន្ធនឹងការថ្លែងសំអាងចំពោះទម្រង់ខុសៗទាំងបីនៃសហឧក្រិដ្ឋកម្មរួម ។

ដូច្នេះ វាជាការលំបាកចំពោះអង្គបុរេជំនុំជម្រះ ក្នុងការកំណត់លើអ្វីដែលបានចោទប្រកាន់ និងអង្គហេតុដែលយកមកធ្វើជាសំអាង ចំពោះលក្ខខណ្ឌនៃធាតុផ្សំផ្នែកច្បាប់លើទម្រង់នីមួយៗនៃសហឧក្រិដ្ឋកម្មរួម ។ ការថែងបញ្ជាក់ គឺជាលក្ខខណ្ឌចាំបាច់ដើម្បីធ្វើការវិភាគថា តើទម្រង់ខុសៗគ្នានៃសហឧក្រិដ្ឋកម្មរួមគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ? ហេតុដូច្នេះហើយ អាចយកមកអនុវត្តបាន។

ការបញ្ជាក់ឱ្យបានច្បាស់លាស់ក៏ដូចជាលក្ខខណ្ឌចាំបាច់ផងដែរដើម្បីធ្វើការវែកញែកទស្សនទាននៃសហកម្មឧក្រិដ្ឋកម្មរួម ពីទម្រង់នៃការទទួលខុសត្រូវប្រភេទផ្សេងៗទៀត ដែលអាចនៅជាធរមានអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

វាក្យខណ្ឌ៧៣: អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ចំណុចសំខាន់ គឺលក្ខខណ្ឌពិសេសនៃសញ្ញាណរបស់សហឧក្រិដ្ឋកម្មរួម យ៉ាងហោចណាស់ចំពោះទម្រង់មូលដ្ឋាន ឋិតនៅត្រង់ការចង្អុលបញ្ជាក់លើបរិបទរបស់វា ។ ចំណុចនេះ អនុញ្ញាតឱ្យការទទួលខុសត្រូវរបស់បុគ្គលនីមួយៗក្នុងនាមជាសហចារី ចងភ្ជាប់ជាមួយនឹងអ្នកចូលរួមនៅក្នុងសកម្មភាពឧក្រិដ្ឋកម្មរួម ទោះបីជាបុគ្គលទាំងនេះ អាចនៅឃ្លាតឆ្ងាយពីការប្រព្រឹត្តិបទល្មើសជាក់ស្តែងដោយផ្ទាល់ក៏ដោយ។ ការទទួលខុសត្រូវលើសហកម្មឧក្រិដ្ឋកម្មរួម មានធាតុអត្តនោម័តិផ្តោតលើគោលបំណងរួមនិងចេតនារបស់អ្នកចូលរួម ។ ដូច្នេះបើ ឌុច នឹងត្រូវគេចោទប្រកាន់ថា ជាអ្នកចូលរួមមែននោះ នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ការយល់ឃើញលើកម្រិត និងវិសាលភាពនៃការទទួលខុសត្រូវរបស់គាត់ នឹងអាចខុសពីការរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងធាតុផ្សំនៃចេតនា។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឆ្លុះបញ្ចាំងពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលលើកឡើងពីការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ ឌុច ចំពោះតួនាទីនៅក្នុងរចនាសម្ព័ន្ធ

នៃឋានានុក្រមរបស់មន្ទីរស-២១ ។

អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថាសហកម្ម ឧក្រិដ្ឋកម្មនៅមន្ទីរស-២១ ដែលគេបានចោទប្រកាន់ គឺមានការពង្រីកលើប្រភេទនៃការប្រព្រឹត្តិដែលជាប់ពាក់ព័ន្ធនឹង ឌុច ។

វាក្យខណ្ឌ៧៤: អង្គបុរេជំនុំជម្រះយល់ឃើញថា ធាតុផ្សំមួយចំនួនចំពោះការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ដូចដែលបានលើកឡើងនៅក្នុងសហកម្ម ឧក្រិដ្ឋកម្មរួមនៅមន្ទីរស-២១ អាចត្រូវបានគេយល់ថា បានបង្កើតជាផ្នែកមួយនៃការស៊ើបសួរ ខណៈដែលធាតុផ្សំដទៃទៀតចំពោះទម្រង់ទាំងបីនៃសហឧក្រិដ្ឋកម្មរួម គឺមិនត្រូវបានយកមកធ្វើការស៊ើបសួរឡើយ ។ ដូច្នេះ វាមិនមែនជាបញ្ហានៃការកំណត់បទចោទដូចដែលសហព្រះរាជអាជ្ញាលើកឡើងនោះទេដោយសារតែវាមិនមានមូលដ្ឋានអង្គហេតុគ្រប់គ្រាន់ក្នុងការកំណត់បទចោទ ។

VII. សិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទ

វាក្យខណ្ឌ៧៥: នីតិវិធីសម្រាប់កិច្ចស៊ើបសួរនៅ អ.វ.ត.ក ដែលបានចែងនៅក្នុងវិធាននៃ្ទក្នុងបង្កើតឡើងក្នុងគោលបំណងធានានូវភាពយុត្តិធម៌ដល់ជនត្រូវចោទ ។ ចំពោះការជូនដំណឹងអំពីវិសាលភាពនិងលក្ខណៈនៃអំពើដែលស្ថិតក្រោមការស៊ើបអង្កេត ហើយដែលជនត្រូវចោទអាចត្រូវបានគេបញ្ជូនទៅជំនុំជម្រះដោយផ្អែកលើវិសាលភាពនិងលក្ខណៈនៃអំពើទាំងនេះ ។

អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ជនត្រូវចោទមានសិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទនៅក្នុងដំណាក់កាលស៊ើបសួរ ត្រឹមកម្រិតមួយដែលអាចឱ្យគាត់អនុវត្តសិទ្ធិ ដែលផ្តល់ជូនគាត់នៅអំឡុងពេលនៃការស៊ើបសួរ។ សិទ្ធិទាំងនោះ រួមមានសិទ្ធិស្នើសុំឱ្យបើកកិច្ចស៊ើបសួរ អនុលោមតាមវិធាន៥៨.៦ ។

វាក្យខណ្ឌ៧៦: អង្គបុរេជំនុំជម្រះ យោងលើវិធាន២១ និងវិធាន៥១ នៃវិធាននៃ្ទក្នុង ។

វាក្យខណ្ឌ៧៧: ជនត្រូវចោទមិនត្រូវបានគេជូនដំណឹង អំពីការចោទប្រកាន់ចំពោះការចូលរួមរបស់គាត់នៅក្នុងសហកម្ម ឧក្រិដ្ឋកម្មរួមនៅមន្ទីរស-២១ មុនពេលចេញដីកាសន្និដ្ឋានស្ថាពរ ។ សហកម្ម ឧក្រិដ្ឋកម្មរួមនៅមន្ទីរស-២១ មិនបានបង្កើតជាផ្នែកមួយនៃមូលដ្ឋានអង្គហេតុសម្រាប់ការស៊ើបសួរ ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះមិនអាចបន្ថែមបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងដំណាក់កាលនេះឡើយ ។

វាក្យខណ្ឌ៧៨: ដោយពិចារណាលើសំអាងហេតុ និងសេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះ

វាមិនជាការចាំបាច់ក្នុងការសម្រេចបញ្ហាចោទ អំពីឋានៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ស្តីពីការទទួលខុសត្រូវលើសហកម្ម ឧក្រិដ្ឋកម្មរួមនៅក្នុងអំឡុងពេលមានបទល្មើសដែលគេចោទប្រកាន់នេះឡើយ ។

ដូចគ្នានេះដែរ វាក៏មិនមានភាពចាំបាច់ក្នុងការសម្រេចចំពោះការអនុវត្តនៃការទទួលខុសត្រូវលើសហកម្ម ឧក្រិដ្ឋកម្មរួមនៅពេលប្រៀបធៀបជាមួយនិងទម្រង់នៃការទទួលខុសត្រូវដទៃទៀត នៅចំពោះមុខ អ.វ.ត.ក តាមច្បាប់កម្ពុជា ។

VI. ការឃុំខ្លួនបណ្តោះអាសន្ន

វាក្យខណ្ឌ៧៩:អង្គបុរេជំនុំជម្រះយល់ស្របជាមួយសហចៅក្រមស៊ើបអង្កេតថា មូលដ្ឋានចំនួនបីផ្សេងៗទៀត ដែលមាននៅក្នុងសាលដីកាលើកមុននៅជាធរមាន ធានាវត្តមានរបស់ជនត្រូវចោទនៅក្នុងពេលដំណើរការនីតិវិធី ការពារសន្តិសុខរបស់ជនត្រូវចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ ។

វាក្យខណ្ឌ៨០: ដោយផ្អែកលើមូលដ្ឋានទាំងនេះ អង្គបុរេជំនុំជម្រះ បង្គាប់ឱ្យបន្តការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នរហូតដល់ពេលជនត្រូវចោទចូលខ្លួនមុខអង្គជំនុំជម្រះសាលាដំបូង ។

ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖

១) បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់ ។

២) ទទួលយកមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ផ្នែកមួយចំនួន ។

៣) ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានកែប្រែដោយបន្ថែមសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ។ បង្គាប់ឱ្យយកវាក្យខណ្ឌខាងក្រោមមកជំនួសវាក្យខណ្ឌទី១៥២ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

អំពើជាក់លាក់ដែលបង្ហាញតាមកិច្ចស៊ើបសួរ ក៏បង្កើតជាបទល្មើសនៃការធ្វើទារុណកម្មដើម្បីឱ្យឈឺជាខ្លាំង ហើយធ្លាយប្រាប់ព័ត៌មានផ្សេងៗដែលមានប្រយោជន៍ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មឬមជ្ឈិមណាមួយក្តី និងបទមនុស្សឃាត អនុលោមតាមច្បាប់ជាតិ ។ បទល្មើសនេះ ត្រូវបានកំណត់តាម មាត្រា៥០០ មាត្រា៥០១ និងមាត្រា៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។

កែប្រែ: វាក្យខណ្ឌ១៥៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយបន្ថែមចំណុចដូចខាងក្រោម៖

ឌុច មិនត្រូវបានចោទប្រកាន់ពីបទ ទម្រង់នៃការទទួលខុសត្រូវលើការប្រព្រឹត្តិបទទារុណកម្មឡើយ ។

កែប្រែ: ផ្នែកទីបួននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយបន្ថែម៖

៣) ការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បទមនុស្សឃាតមាត្រា៥០១ និងមាត្រា៥០៦ ។ បទទារុណកម្ម មាត្រា៥០០ ដែលជាបទល្មើសចែងនិងផ្តន្ទាទោសតាមមាត្រា៣(ថ្មី) មាត្រា២៩ (ថ្មី) មាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ ។

៤) បដិសេធចោលផ្នែកដទៃទៀតនៃបណ្តឹងឧទ្ធរណ៍ ។

៥) ចោទប្រកាន់ កាំង ហ្គេកអ៊ាវ ហៅ ឌុច និងបញ្ជូនជននេះទៅជំនុំជម្រះដូចមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយដីកានេះត្រូវឱ្យស្របទៅនឹងសាលដីកានេះ ។

៦) បន្តឃុំខ្លួន កាំង ហ្គេកអ៊ាវ ហៅ ឌុច ដោយផ្អែកលើមូលហេតុដូចមានចែងក្នុងសាលដីកានេះរហូតដល់ពេលជននេះ ចូលខ្លួនមុខអង្គជំនុំជម្រះសាលាដំបូង ។

៧) បញ្ជូនសំណុំរឿងលេខ ០០១/១៨-០៧-២០០៧ អ.វ.ត.ក/កសចស ទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ។ សាលដីកានេះ បិទផ្លូវតវ៉ាអនុលោមតាមវិធាន៧៧.១៣ នៃវិធានផ្ទៃក្នុង ។ សាលដីកានេះប្រកាសជាសាធារណៈដោយអង្គបុរេជំនុំជម្រះ នៅចំពោះមុខជនត្រូវចោទនិងសហមេធាវីការពារក្តីរបស់ជនត្រូវចោទ ។ ភ្នំពេញ ថ្ងៃទី៥ ធ្នូ ឆ្នាំ២០០៨

ប្រធានកងការពារនាំជនត្រូវចោទទៅកាន់មន្ទីរឃុំឃាំង !

ប្រកាសបិទសវនាការ ៕

*(សវនាការបញ្ចប់នៅម៉ោង១៦:៣១នាទី)*